**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១២៣ ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើត និងបំបែកភូមិ នៃខេត្តកំពង់ចាម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ចាម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត **ភូមិបឹងកុកទី៣** ដោយបំបែកចេញពីភូមិបឹងកុកទី២ នៃសង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិទី៦ «ក»** ដោយបំបែកចេញពីភូមិទី៦ នៃសង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

**ប្រការ ២.-**

ត្រូវបានបង្កើត ភូមិទី១៥ ដោយបំបែកចេញពីភូមិទី១៣ នៃឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។

**ប្រការ ៣.-**

ត្រូវបានបំបែកភូមិបឹងត្រាវ នៃឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម ជាពីរ គឺភូមិបឹងត្រាវត្បូង និង ភូមិបឹងត្រាវជើង។

ត្រូវបានបំបែកភូមិព្រែកគ្រួស នៃឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម ជាពីរ គឺភូមិព្រែកគ្រួសកើត និង ភូមិព្រែកគ្រួសលិច។

ត្រូវបានបំបែកភូមិទួលបី នៃឃុំរាយប៉ាយ ស្រុកកងមាស ខេត្តកំពង់ចាម ជាពីរ គឺភូមិទួលបីទី១ និង ភូមិទួលបីទី២។

ត្រូវបានបង្កើត **ភូមិពោធិ៍មានជ័យ** ដោយបំបែកចេញពីភូមិរាយប៉ាយលើ នៃឃុំរាយប៉ាយ ស្រុកកងមាស ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិរាយប៉ាយកណ្ដាល** ដោយបំបែកចេញពីភូមិរាយប៉ាយក្រោម នៃឃុំរាយប៉ាយ ស្រុកកងមាស ខេត្តកំពង់ចាម។

**ប្រការ ៤.-**

ត្រូវបានបង្កើត **ភូមិភ្នំវិហារ** ដោយបំបែកចេញពីភូមិបឹងវែង នៃឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិស្រះតាប៉ែន** ដោយបំបែកចេញពីភូមិជើងព្រៃ នៃឃុំជើងព្រៃ ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិត្រពាំងចក** ដោយបំបែកចេញពីភូមិកប៉ាល់ នៃឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិបន្ទាយចាស់** ដោយបំបែកចេញពីភូមិពោធិស្បៀង នៃឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិកកោះ** ដោយបំបែកចេញពីភូមិស្វាយព្រៃ នៃឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិជុំម្សៅ** ដោយបំបែកចេញពីភូមិតាំងជ្រៃ នៃឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិតាពន់** និង **ភូមិត្រពាំងថ្លា** ដោយបំបែកចេញពីភូមិសំបួរ នៃឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម។

ត្រូវបានបង្កើត **ភូមិផ្សារផ្អាវ** ដោយបំបែកចេញពីភូមិផ្អាវ នៃឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម។

**ប្រការ ៥.-**

ត្រូវបានបំបែកភូមិល្វា នៃឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាពីរ គឺភូមិល្វា១ និង ភូមិល្វា២។

ត្រូវបានបំបែកភូមិបែកអន្លូង នៃឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាពីរ គឺភូមិបែកអន្លូង១ និង ភូមិបែកអន្លូង២។

ត្រូវបានបំបែកភូមិព្រែកបាក់ នៃឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាពីរ គឺភូមិព្រែកបាក់១ និង ភូមិព្រែកបាក់២។

ត្រូវបានបំបែកភូមិបឹងដែង នៃឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាពីរ គឺភូមិបឹងដែង១ និង ភូមិបឹងដែង២។

**ប្រការ ៦.-**

ត្រូវបានបង្កើត ភូមិសណ្ដាន់ និង ភូមិនគរបាជ័យ ដោយបំបែកចេញពីភូមិអំពិលលើ នៃឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

**ប្រការ ៧.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលភូមិបង្កើតថ្មីដូចមានចែងនៅក្នុងប្រការ១ ប្រការ២ ប្រការ៣ ប្រការ៤ ប្រការ៥ និងប្រការ៦ នៃប្រកាសនេះ ត្រូវអនុលោមទៅតាមសេចក្ដីណែនាំលេខ ០០៤ សណន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្ដីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានកសុ្ភារនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តកំពង់ចាម គណៈអភិបាលខេត្តកំពង់ចាម ក្រុមប្រឹក្សាក្រុងកំពង់ចាម ស្រុកកោះសូទិន ស្រុកកងមាស ស្រុកបាធាយ ស្រុកស្ទឹងត្រង់ និងស្រុកកំពង់សៀម គណៈអភិបាលក្រុងកំពង់ចាម ស្រុកកោះសូទិន ស្រុកកងមាស ស្រុកបាធាយ ស្រុកស្ទឹងត្រង់ និងស្រុកកំពង់សៀម និងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារកាលប្បវត្តិ